# នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង
# អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

## ព័ត៌មានពិស្តារអំពីការដាក់ឯកសារ

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ

ភាគីដាក់ឯកសារ: មេធាវីការពារក្តី អៀង សារី

ដាក់ជូន: អង្គជំនុំជម្រះសាលាដំបូង

ភាសាដើម: អង់គ្លេស

កាលបរិច្ឆេទឯកសារ: ថ្ងៃទី ៣ ខែ កុម្ភៈ ឆ្នាំ ២០១២

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 03-Feb-2012, 11:45
CMS/CFO: Sann Rada

## ចំណាត់ថ្នាក់ឯកសារ

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: **សាធារណៈ**

ចំណាត់ថ្នាក់ឯកសារដោយ ក.ស.ច.ស ឬ អង្គជំនុំជម្រះ **សាធារណៈ/Public**

ចំណាត់ថ្នាក់ប្រភេទឯកសារ

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់ណ្តោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

---

**ចម្លើយតបរបស់លោក អៀង សារី ទៅនឹងសំណើរបស់សហព្រះរាជអាជ្ញា សុំដាក់បញ្ចូលទីតាំងឧក្រិដ្ឋបន្ថែមទៅក្នុងវិសាលភាពនៃការជំនុំជម្រះលើរឿងក្តី ០០២/០១**

---

**ដាក់ដោយ ÷**

**មេធាវីការពារក្តី ÷**

អាង ឧត្តម

Michael G. KARNAVAS

**ទៅក្រុមអង្គជំនុំជម្រះសាលាដំបូង ÷**

ចៅក្រម **និល ណុន**

ចៅក្រម **យ៉ូរ ឧត្តរា**

ចៅក្រម **យ៉ា សុខន**

ចៅក្រម Silvia CARTWRIGHT

ចៅក្រម Jean-Marc LAVERGNE

ចៅក្រមបម្រុង **ធូ មណី**

ចៅក្រមបម្រុង Claudia FENZ

**ចម្លងជូន ÷**

**សហព្រះរាជអាជ្ញា ÷**

ជា លាង

Andrew CAYLEY

**មេធាវីការពារក្តីទាំងអស់**

**ដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់**

លោក អៀង សារី តាមរយៈសហមេធាវីការពារក្តីរបស់លោក “មេធាវីការពារក្តី” សូមធ្វើការឆ្លើយតបទៅនឹងសំណើរបស់សហព្រះរាជអាជ្ញា សុំដាក់បញ្ចូលទីតាំងឧក្រិដ្ឋបន្ថែមទៅក្នុងវិសាលភាពនៃការជំនុំជម្រះលើរឿងក្តី ០០២/០១ (“សំណើរបស់ កសព”)[1]។ សំណើរបស់ កសព នេះគឺជាការប៉ុនប៉ងជាថ្មីមួយទៀតដោយ កសព ដើម្បីស្នើសុំដល់ អង្គជំនុំជម្រះសាលាដំបូង អោយពិចារណាសារឡើងវិញនូវដីកាបំបែកដំណើរការនីតិវិធីរបស់ខ្លួន[2]។ មេធាវីការពារក្តី លុះត្រាណាតែមានការណែនាំជាក់លាក់ដោយអង្គជំនុំជម្រះសាលាដំបូង មិនមានបំណងឆ្លើយតបទៅលើខ្លឹមសារនៃសំណើរបស់ កសព ឡើយ ។ សំណើរបស់ កសព នេះគួរត្រូវបដិសេធចោលដោយសង្ខេប។ *ការដាក់សារណាជាច្រើនដែលគ្មានមូលដ្ឋានទាំងស្រុង គឺបំពានទៅលើដំណើរការរបស់ អវតក និងថែមបន្ទុកដល់ធនធានដែលមិនមានគ្រប់គ្រាន់ និងពេលវេលារបស់អង្គជំនុំជម្រះ ក៏ដូចជារបស់ភាគីទាំងឡាយ*។ ខណៈពេលដែលវិធានផ្ទៃក្នុង មិនមានចែងអំពីវិធានការដាក់ទោសទណ្ឌចំពោះការរំលោភបំពាននៃដំណើរការនីតិវិធីនេះ ទាក់ទងនឹងការអនុវត្តរបស់ កសព ដែលចេះតែបន្តដាក់សំណើសុំការពិចារណាឡើងវិញជាច្រើន (ថ្វីត្បិតមានចំណងជើងផ្សេងគ្នាក៏ដោយ) អង្គជំនុំជម្រះសាលាដំបូង គួរប្រើប្រាស់នូវឆន្ទានុសិទ្ធិរបស់ខ្លួនដើម្បីពិចារណាវិធានការទាំងឡាយដែលមានលក្ខណៈសមរម្យ ដើម្បីធានាថា កសព បញ្ឈប់ និងលះបង់នូវការអនុវត្តបែបនេះ។

**អាស្រ័យហេតុនេះ** ដោយផ្អែកលើមូលហេតុទាំងអស់ដែលបានបញ្ជាក់ខាងលើ មេធាវីការពារក្តីស្នើដោយគោរពដល់អង្គជំនុំជម្រះសាលាដំបូងមេត្តា ៖

ក. **បដិសេធ** សំណើរបស កសព

ខ. **ពិចារណា** វិធានការទាំងឡាយដែលមានលក្ខណៈសមរម្យ ដើម្បីធានាថា កសព បញ្ឈប់ការប៉ុនប៉ងដដែលៗ ដើម្បីស្នើសុំអោយពិចារណាសារជាថ្មី នៃដីកាបំបែកកិច្ចដំណើរការនីតិវិធី និង

---

[1] សំណើរបស់ កសព សុំអោយដាក់បញ្ចូលនូវទីតាំងឧក្រិដ្ឋកម្មបន្ថែមនានាដែលឋិតក្នុងវិសាលភាពនៃសំណុំរឿង ០០២/០១ ចុះថ្ងៃទី ២៧ មករា ២០១២ ឯកសារលេខ E163។

[2] សូមមើល ការជូនដំណឹងរបស់សហព្រះរាជអាជ្ញា អំពីសំណើសុំការពិចារណាឡើងវិញនូវខ្លឹមសារនៃ “ដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធីអនុលោមតាមវិធានផ្ទៃក្នុង ៨៩ ស្ទួនពីរ” ចុះថ្ងៃទី ២៣ កញ្ញា ២០១១ ឯកសារលេខ E124/1។ សំណើរបស់សហព្រះរាជអាជ្ញា សុំការពិចារណាឡើងវិញនូវ “ដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធីអនុលោមតាមវិធានផ្ទៃក្នុង ៨៩ ស្ទួនពីរ” ចុះថ្ងៃទី ៣ តុលា ២០១១ ឯកសារលេខ E124/2។ សំណើរបស់សហព្រះរាជអាជ្ញាសុំអោយពិចារណាឡើងវិញនូវវិសាលភាពនៃការជំនុំជម្រះក្តីលើកទី១ ចុះថ្ងៃទី ៤ វិច្ឆិការ ២០១១ ឯកសារលេខ E124/9។

គ. **បន្ទាប់** មិនអោយមានការដាក់សំណើឆ្លើយតបដោយ កសព ទៅលើបញ្ហានេះ។

មេធាវីការពារក្តីសូមដាក់ជូនសំណើនេះដោយគោរព។

_______________ _______________

អាង ឧត្តម Michael G. KARNAVAS

សហមេធាវីការពារក្តី អៀង សារី

ចុះហត្ថលេខា នៅរាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា នៅថ្ងៃទី **៣** ខែ **កុម្ភៈ ឆ្នាំ ២០១២**